ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តកណ្តាល

សំណុំរឿងព្រហ្មទណ្ឌ
លេខ ១៦៥៣ អ.ក
ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២១
សាលក្រម
លេខ ៣៩ "ផ"ក្រ
ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១

# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកណ្តាល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២១ វេលាម៉ោង ០៩ និង ០០នាទីព្រឹក ដោយមានសមាសភាពចូលរួមដូចខាងក្រោម៖

## ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ប្រធានក្រុមប្រឹក្សាជំនុំជម្រះ
លោក ចៅក្រមប្រឹក្សា
លោក ចៅក្រមប្រឹក្សា

## តំណាងអយ្យការ

លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

## ក្រឡាបញ្ជីសវនាការ

លោក [redacted] ក្រឡាបញ្ជីនៃសាលាដំបូងខេត្តកណ្តាល

-ដើម្បីធ្វើការជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១៦៥៣ អ.ក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ ដែលមានជនជាប់ចោទដូចខាងក្រោម៖

-ឈ្មោះ [redacted] សោភ័ណ្ឌ ហៅ ឡូត ភេទប្រុស អាយុ៣៨ ឆ្នាំ ជនជាតិខ្មែរ មុខរបរកសិករ ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកណ្តាល ទីលំនៅបច្ចុប្បន្ននៅភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] សុខ (ស្លាប់) ម្តាយឈ្មោះ [redacted] មុក (រស់) ប្រពន្ធឈ្មោះ [redacted] គិនរី (លែងលះ) មានកូនចំនួន០៣ នាក់ ជាទីតិជន ទោសពីមុន គ្មាន។

-ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នលេខ ៣៨៤៥ ដកបឃខ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកណ្តាល។

ដោយមានលោកមេធាវី [redacted] អត្តលេខ [redacted] និងលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សោភ័ណ្ឌ។

ជាប់ចោទពីបទ **ឃាតកម្ម (ចាក់សម្លាប់)** ប្រព្រឹត្តនៅភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ បទល្មើសដែលបញ្ញត្តិឱ្យផ្ដន្ទាទោសតាមមាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ។

**-បានឃើញ** របាយការណ៍សរុបលេខ ៣៧១ របក ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ របស់អធិការដ្ឋាននគរបាលក្រុងតាខ្មៅ។

**-បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៖ **១១៨៦** ដកសស ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

-**បានឃើញ** ដីកាសន្និដ្ឋានស្ថាពរលេខ ៖ **១៧៦៣** ដកសព ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្ដាល ។

**-បានឃើញ** ដីកាដំណោះស្រាយលេខ ៖ **១៨៣៥** ដកដស ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តកណ្ដាល ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ វេលាម៉ោង២៣ និង៣០ នាទី ជនជាប់ចោទបានប្រច័ណ្ឌជាមួយនារីជនរងគ្រោះ ដោយសង្ស័យថាមានប្រុសថ្មីទៀត ក៏បានលួចតាមដាននារីជាជនរងគ្រោះកំពុងអង្គុយផឹកស្រាបៀរជាមួយមនុស្សប្រុសចំនួន០៣ ទៅ០៤ នាក់ នៅលើផ្លូវ២១៥ ភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្ដាល ពេលនោះជនសង្ស័យបានស្រែកឱ្យជនរងគ្រោះឱ្យចេញមកក្រៅដើម្បីនិយាយគ្នាឱ្យដឹងខុសត្រូវ តែនៅពេលដែលកំពុងដើរនិយាយគ្នានោះ ក៏កើតមានជម្លោះឡើងរហូតជនជាប់ចោទដកកូនកាំបិតចុងស្រួចដែលលាក់ទុកក្នុងហោប៉ៅ យកមកចាក់ជនរងគ្រោះចំនួន០៣ កន្លែង បណ្ដាលឱ្យដេកស្លាប់ក្នុងថ្លុកឈាម។ ក្រោយពីធ្វើសកម្មភាពរួចហើយបានជិះមកសារភាពកំហុសនៅប៉ុស្ដិ៍នគរបាលរដ្ឋបាលអំពៅព្រៃ រួចនគរបាលប៉ុស្ដិ៍អំពៅព្រៃក៏បានទាក់ទងមកកាន់អធិការដ្ឋាននគរបាលក្រុងតាខ្មៅដើម្បីទទួលយកជនជាប់ចោទមកចាត់ការតាមនីតិវិធី។

## នាពេលសវនាការ

-តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] សោភ័ណ្ឌ ហៅ ឡូត បានឆ្លើយថា កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ ខ្លួនបានទៅតាមមិត្តស្រីដែលកំពុងផឹកស៊ីជាមួយមិត្តភក្តិ ស្រាប់តែមិត្តភក្តិគាត់បានរករឿងចង់វាយខ្លួន។ ខ្លួនក៏បានហៅមិត្តស្រីខ្លួនឱ្យចេញមកនិយាយគ្នា ហើយមិត្តស្រីខ្លួនក៏បានចេញមក ហើយខ្លួនក៏បានទាញយកកូនកាំបិតពីតុផឹកស៊ីយកមកកាន់ជាប់ដៃ។ ពេលចេញមកតាមផ្លូវ ខ្លួន និងមិត្តស្រីបានឈ្លោះប្រកែកគ្នា ហើយគាត់បានជេរខ្លួនថា ពេលនោះខ្លួនក៏ខឹង ហើយយកកាំបិតចាក់មិត្តស្រីខ្លួនចំនួន ០៣ កាំបិត បណ្ដាលឱ្យស្លាប់តែម្ដង។ ពេលចាក់ហើយខ្លួនក៏បានជិះម៉ូតូមកប៉ុស្ដិ៍ប៉ូលីសដើម្បីសារភាពកំហុស។ ខ្លួនទើបតែវះកាត់ខួរក្បាលរួច មុនពេលប្រព្រឹត្តបទល្មើស ០៤ ខែ ដោយសារឈាមកកក្នុងខួរក្បាល។ ខ្លួន



Scanned with CamScanner

ស្រលាញ់មិត្តស្រីខ្លួនពេក ហើយគាត់មានថ្មី ទើបខ្លួនខឹងទប់អារម្មណ៍មិនជាប់ ទើបចាក់សម្លាប់គាត់។ ខ្លួនដាក់កាំបិតមកតាមខ្លួនព្រោះខ្លួនខ្លាចមិត្តភក្តិគាត់រករឿង ព្រោះមុនហ្នឹងខ្លួនត្រូវបានមិត្តភក្តិគាត់គំរាមរកវាយខ្លួន។ ខ្លួនមិនមានចេតនារកចាក់សម្លាប់គាត់ទេ គឺដោយសារកំហឹងទើបខ្លួនចាក់យកៗតែម្តង។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] កុសល បានឆ្លើយថា នៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ នៅវេលាម៉ោងប្រហែលដប់មួយកន្លះយប់ ឈ្មោះ [redacted] សោភ័ណ្ឌ ត្រូវជាប្អូនថ្លៃរបស់ខ្លួនបានទូរស័ព្ទប្រាប់ខ្លួនថា វាបានចាក់សម្លាប់ប្អូនស្រីរបស់ខ្លួនឈ្មោះ [redacted] ស្រីកែវ ស្លាប់ហើយ សុំឱ្យខ្លួនមកយកសាកសពទៅក្រៅពីនេះខ្លួនមិនបានដឹងរឿងអ្វីទៀតនោះទេ។ ខ្លួនសូមសំណូមពរឱ្យឈ្មោះ [redacted] សោភ័ណ្ឌ សងជំងឺចិត្តចំនួន ១០,០០០ (មួយម៉ឺន) ដុល្លារអាមេរិក។

**<u>សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ</u>**

ឆ្លងតាមការសួរដេញដោលនាពេលសវនាការ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] សោភ័ណ្ឌ ហៅ ឡូត ពិតជាបានយកកាំបិតចាក់សម្លាប់ជនរងគ្រោះប្រាកដមែន ដោយសារការប្រច័ណ្ឌ និងឈ្លោះប្រកែកគ្នា ឃើញថាមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ ហេតុនេះតំណាងអយ្យការស្នើសុំរក្សាបទចោទប្រកាន់ដូចមានក្នុងដីកាសន្និដ្ឋានស្ថាពរលេខ **១៧៦៣ ដកសព** ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២០ និងស្នើសុំតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

**<u>សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ</u>**

លោកមេធាវី [redacted] បានធ្វើសេចក្តីសន្និដ្ឋានថាក្រោយពីបញ្ចប់ការសួរដេញដោលនាពេលសវនាការ ឃើញថា កូនក្តីខ្លួនបានសារភាពកំហុសរបស់ខ្លួន សំណូមពរសូមឱ្យតុលាការជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនជាអប្បបរមា កូនក្តីខ្លួនមានកម្រិតវប្បធម៌ទាប មានបញ្ហាស្មារតីទើបតែវះកាត់យកឈាមកកក្នុងខួរក្បាលរួច ម្យ៉ាងទៀតកូនក្តីខ្លួនទើបតែប្រព្រឹត្តបទល្មើសជាលើកដំបូង ហើយនៅក្នុងពន្ធនាគារកូនក្តីខ្លួនបានគោរពវិន័យ មិនបង្កផលវិបាកអ្វីដល់ពន្ធនាគារឡើយ។

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យភស្តុតាង និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

**១.**កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ ស្ថិតនៅភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល ពិតជាមានករណី **ឃាតកម្ម** (ចាក់សម្លាប់) កើតឡើង ប្រាកដមែន។



Scanned with CamScanner

**២**.អំពើល្មើសនេះត្រូវបានបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] **សោភ័ណ្ឌ** ហៅ **ឡូត** ដោយជនជាប់ចោទបានឈ្លោះប្រកែកជាមួយជនរងគ្រោះ ក៏បានដកយកកូនកាំបិតចុងស្រួចដែលលាក់ទុកក្នុងហោប៉ៅចាក់ទៅលើជនរងគ្រោះឈ្មោះ [redacted] **ស្រីកែវ** ចំនួន ០៣ កាំបិទ បណ្តាលឱ្យស្លាប់។

**៣**.ជនជាប់ចោទឈ្មោះ [redacted] **សោភ័ណ្ឌ** បានសារភាពថាខ្លួនពិតជាបានចាក់សម្លាប់ជនរងគ្រោះឈ្មោះ [redacted] **ស្រីកែវ** បណ្តាលឱ្យស្លាប់ប្រាកដមែន ដោយសារខ្លួនខឹង និងឈ្លោះគ្នាជាមួយជនរងគ្រោះ។

**៤**.ជនជាប់ចោទឈ្មោះ [redacted] **សោភ័ណ្ឌ** ហៅ **ឡូត** ជាសមត្ថជនមានស្មារតីល្អគ្រប់គ្រាន់ ក្នុងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនូវរាល់អំពើដែលខ្លួនបានប្រព្រឹត្តចំពោះមុខច្បាប់។

**៥**.អំពើល្មើស និងសកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] **សោភ័ណ្ឌ** ហៅ **ឡូត** បានធ្វើឱ្យប៉ះដល់របៀបរៀបរយសាធារណៈ និងប៉ះពាល់ដល់អាយុជីវិតអ្នកដទៃ ដែលច្បាប់បានការពារ និងតម្រូវឱ្យផ្តន្ទាទោស។

**៦**.មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **សោភ័ណ្ឌ** ហៅ **ឡូត** ពីបទ **ឃាតកម្ម (ចាក់សម្លាប់)** ប្រព្រឹត្តនៅភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា **១៩៩** នៃក្រមព្រហ្មទណ្ឌ។

**៧**.ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **កុសល** បានធ្វើការទាមទារសំណងជំងឺចិត្តចំនួន **១០,០០០** (មួយម៉ឺន) ដុល្លារអាមេរិក គប្បីតុលាការយកមកពិចារណាតាមទំហំនៃព្យសនកម្មដែលទទួលរង។

**៨.វត្ថុចាប់យករួមមាន៖**

-ម៉ូតូមួយគ្រឿងម៉ាក HONDA DREAM ស្លាកលេខ កណ្តាល 1W - 8667 ពណ៌ខ្មៅ លេខម៉ាស៊ីន ND125ME-9818418 លេខតួ ND125M-9818418 (ត្រូវបានចៅក្រមស៊ើបសួរសម្រេចប្រគល់ឱ្យម្ចាស់ដើមវិញតាមដីកាសម្រេចលេខ ៤០៤៤ ដកស/២០ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០)

-កូនកាំបិតចុងស្រួចចំនួន០១ (មួយ) ផ្លែដែក ដងជ័រពណ៌លឿង ប្រវែង២១ សង់ទីម៉ែត្រ ។

-ម្លូកសុវត្ថិភាពចំនួន០១ (មួយ) ពណ៌ស។

គប្បីតុលាការពិចារណាតាមច្បាប់។

## ហេតុដូច្នេះសម្រេច

**១**-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted] **សោភ័ណ្ឌ** ហៅ **ឡូត** ភេទប្រុស អាយុ៣៨ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរកសិករ(មានអត្តសញ្ញាណដូចខាងលើ) ដាក់ពន្ធនាគារកំណត់ **១០(ដប់)ឆ្នាំ**។

ពីបទ **ឃាតកម្ម (ចាក់សម្លាប់)** ប្រព្រឹត្តនៅភូមិព្រែកហូរកើត សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ ខេត្តកណ្តាល កាលពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២០ បទល្មើសដែលបញ្ញត្តិឱ្យផ្តន្ទាទោសតាមមាត្រា **១៩៩** នៃក្រមព្រហ្មទណ្ឌ។

**២**-បង្គាប់ឱ្យជនជាប់ចោទឈ្មោះ [redacted] **សោភ័ណ្ឌ** ហៅ **ឡូត** សងសំណងជំងឺចិត្តចំនួន **៤០,០០០,០០០ (សែសិបលាន) រៀល** ឱ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **កុសល**។



Scanned with CamScanner

**៣-វត្ថុចាប់យកមាន៖**

ក-វត្ថុចាប់យកត្រូវប្រគល់ឱ្យម្ចាស់ដើមវិញ

-ម៉ូតូមួយគ្រឿងម៉ាក HONDA DREAM ស្លាកលេខ កណ្ដាល 1W - 8667 ពណ៌ខ្មៅ លេខម៉ាស៊ីន ND125ME-9818418 លេខតួ ND125M-9818418

**ខ-វត្ថុចាប់យកត្រូវរឹបអូសមាន៖**

-កូនកាំបិតចុងស្រួចចំនួន០១ (មួយ) ផ្លែដែក ដងជ័រពណ៌លឿង ប្រវែង២១ សង់ទីម៉ែត្រ ។

-មួកសុវត្ថិភាពចំនួន០១ (មួយ) ពណ៌ស។

សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២១ ចំពោះមុខជនជាប់ចោទ ឈ្មោះ [redacted] **សោភ័ណ្ឌ** ហៅ **ឡូត** ចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] កុសល និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១។

ទុកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់៕

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា |

[redacted]

.................................................................................................................

**"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"**

ថ្ងៃពុធ ២កើត ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

កណ្ដាល, ថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២១

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]